ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា
ប្រចាំនៅទីក្រុងណាននីង
លេខ 00156 កពណក.ណន

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ: របាយការណ៍ប្រចាំ ខែមករា ឆ្នាំ២០១៣**

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបនូវរបាយការណ៍ប្រចាំខែមករា ឆ្នាំ២០១៣ ដោយគោរពដ៏ខ្ពង់ខ្ពស់ដូចតទៅ :

**I. <u>ការទំនាក់ទំនងជាមួយភ្ញៀវ</u> :**

- ចូលរួមសម្ពោធ "4th Golden Camellia Tea Festival" ។
- ជួបក្រុមហ៊ុន **Guangxi Liaochun Trade Co., Ltd.** មានបំណងស្វែងរកទិញអង្ករនៅកម្ពុជា ។
- ជួបក្រុមហ៊ុន **Guangxi Guirentang Golden Camellia Industry Group Co., Ltd.** មានបំណងវិនិយោគដាំតែនៅកម្ពុជា ។
- ជួបក្រុមហ៊ុន **Jiantong International Logistics (Dalian) Co., Ltd.** មានបំណងស្វែងយល់ច្បាប់វិនិយោគនៅកម្ពុជា ។
- ជួបក្រុមហ៊ុន **Xingjiang Fangda Real Estate Development Co., Ltd.** មានបំណងស្វែងរកទិញឈើក្រហម និងសាងសង់ផ្ទះល្វែងនៅកម្ពុជា ។
- ជួប **Guangxi Telecom Industry Group Co., Ltd.** មានបំណងស្វែងរកដៃគូផ្នែកវិនិយោគនៅកម្ពុជា ។
- ជួបក្រុមហ៊ុន **CANKUN International Development Limited & Kingdom Enterprise Co., Ltd.** មានបំណងចង់បើកក្រុមហ៊ុននាំចេញអង្ករនៅកម្ពុជា ។
- ជួបក្រុមហ៊ុន **Hong Sheng Lighting International Co., Ltd.** មានបំណងស្វែងរកទីផ្សារលក់អំពូលភ្លើងដែលជួយសំចៃអគ្គីសនីនៅកម្ពុជា ។
- ជួបក្រុមហ៊ុន **Guangxi Orient Daytong Imp. & Exp. Co., Ltd.** មានបំណងវិនិយោគបើករោងចក្រកាត់ដេរនៅកម្ពុជា ។

**II. ទស្សនវិស័យសេដ្ឋកិច្ចចិនក្នុងឆ្នាំ២០១៣**

ផ្អែកតាមទស្សនៈរបស់ក្រុមសេដ្ឋវិទូចិនបានថ្លែងថា : នៅក្នុងឆ្នាំ២០១៣នេះ សេដ្ឋកិច្ចចិនមានស្ថេរភាព

Address: No 11, Zhujin Road, China-ASEAN Business District,
Nanning City, Guangxi, China
Tel/Fax : +86-771-5389496
Email : clo_cambodia@yahoo.com

ល្អជាងឆ្នាំ២០១២ កន្លងទៅនេះ ហើយរដ្ឋាភិបាលគួរតែពង្រឹងឱ្យបានឆាប់រហ័សនូវការកែទំរង់សេដ្ឋកិច្ចនេះ ។

លោក **Justin Yifu Lin** ជាអតីតអនុប្រធានាធិបតីធនាគារពិភពលោកបានថ្លែងនៅក្នុងឱកាសប្រជុំស្តីអំពីការព្យាករណ៍សេដ្ឋកិច្ចចិន ដែលរៀបចំឡើងដោយគណកម្មការទំនាក់ទំនងជាតិរវាងចិន-អាមេរិកនៅឯមជ្ឈមណ្ឌលស្រាវជ្រាវសេដ្ឋកិច្ចចិនបានថ្លែងថា កំណើនសេដ្ឋកិច្ចចិននឹងកើនបានពី៨-៨.៥%ក្នុងឆ្នាំ២០១៣នេះ។ លោក **Lin** បានផ្តល់យោបល់ថា ដើម្បីឱ្យសេដ្ឋកិច្ចចិនខ្លាំងនិងរឹងមាំល្អនោះ ត្រូវឱ្យមានការវិនិយោគមានជាបន្ត គួបផ្សំចំណូលនិងតម្រូវការក្នុងស្រុករីកចំរើនឆាប់រហ័ស។ លោក **Lin** មានសុទិដ្ឋិនិយមថា ដើម្បីធានាឱ្យកំណើនសេដ្ឋកិច្ចសំរេចបានក៏រិត៨%ជាប្រចាំក្នុងរយៈពេល២០ឆ្នាំទៅមុខនេះ ត្រូវតែមានសក្តានុពលដ៏ធំធេងទាំងផ្នែកឧស្សាហកម្មទាន់សម័យនិងការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធ។ ក្នុងន័យនេះ លោកផ្តល់ជាយោបល់ថា សំខាន់គឺសំដៅលើការកែទំរង់ទីផ្សារនិងកែទំរង់ប្រព័ន្ធសន្តិសុខសង្គម ព្រមទាំងការចែកចាយចំណូលឱ្យបានល្អ ។

លោក **Huang Haizhou** ប្រធានយុទ្ធសាស្ត្រសហប្រតិបត្តិការអន្តរជាតិចិន (**CCIC**) បានថ្លែងថា រដ្ឋាភិបាលថ្មីរបស់ចិនកំពុងតែត្រៀមខ្លួនក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ ដើម្បីធ្វើឱ្យកំណើនសេដ្ឋកិច្ចចិនមិនគ្រាន់តែមានស្ថេរភាពប៉ុណ្ណោះទេ ថែមទាំងមានសន្ទុះសេដ្ឋកិច្ចខ្លាំងទៅមុខទៀតផង។ លោករំពឹងទុកថា កំណើនសេដ្ឋកិច្ចចិននឹងទៅដល់គោលដៅសំរេចបាន៨.១% ក្នុងឆ្នាំ២០១៣នេះ។

យោងតាមការព្យាករណ៍របស់វិទ្យាស្ថានស្រាវជ្រាវរបស់ចិន លោក **Lu Feng** ដែលជានាយកមជ្ឈមណ្ឌលស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចចិនបានបញ្ជាក់ថា នៅក្នុងឆ្នាំ២០១៣នេះកំណើនសេដ្ឋកិច្ចចិននឹងសំរេចបានពី៨.១-៨.២%។ ដោយឡែកផ្នែកតាមក្រុមជំនាញចិនមួយក្រុមបានថ្លែងថា ដើម្បីកែទំរង់ទីផ្សារហិរញ្ញវត្ថុត្រូវ :

១. ពន្លឿនសេរីភាវូបនីយកម្មនៃអត្រាការប្រាក់ ។

២. ត្រូវបញ្ចូលប្រាក់យ៉ន់ទៅក្នុងរូបិយប័ណ្ណអន្តរជាតិ ។

៣. ត្រូវរិតបន្តឹងច្បាប់ទំរង់ធនាគារនិងប្រាក់កម្ចីរបស់រដ្ឋាភិបាល ។

ដោយយោងតាមពត៌មានរបស់ការិយាល័យ ស្ថិតិជាតិរបស់ចិនបានថ្លែងថា : ចាប់ពីឆ្នាំ២000-២០១២ កំណើនសេដ្ឋកិច្ចរបស់ចិនមានការកើនឡើងយឺត១បំផុត គេរំពឹងថា នៅឆ្នាំ២០១៣ កំណើន **GDP** នឹងកើនឡើងវិញ។ ការិយាល័យបានបញ្ជាក់ថា នៅឆ្នាំ២០១២ កំណើនសេដ្ឋកិច្ចចិនសំរេចបានតែ៧.៨%តែប៉ុណ្ណោះ។ កត្តាដែលធ្វើឱ្យសេដ្ឋកិច្ចចិនមានការកើនឡើងយឺត១ គឺសេដ្ឋកិច្ចក្នុងស្រុកមានភាពទន់ខ្សោយនិងកត្តាទីផ្សារអន្តរជាតិសំខាន់១មួយចំនួនរបស់ចិនកំពុងជួបបញ្ហា។ នៅក្នុងឆ្នាំ២០១២កំណើនផលិតផលឧស្សាហកម្មកើនបាន១០% កំណើននៃការលក់រាយកើនបាន១៤.៣% វិនិយោគទុនកើនបាន២០.៦%។ តាមការស្រាវជ្រាវរបស់ទីភ្នាក់ងារ **AFP** បានបញ្ជាក់ថា ឆ្នាំ២០១៣ជាឆ្នាំចាប់ផ្តើមសេដ្ឋកិច្ចរីកចំរើនរបស់ចិន។ លោក **Xi Jinping** ប្រធានាធិបតីថ្មីរបស់ចិនដែលទើបតែឡើងកាន់ដំណែង លោកបានសន្យាថា នឹងធ្វើការកែទំរង់រចនាសម្ព័ន្ធ ការគ្រប់គ្រងរបស់ចិនឡើងវិញ ជាពិសេសរៀបចំឡើងវិញនូវវិធីសាស្ត្រថ្មីក្នុងការអភិវឌ្ឍន៍តាមរយៈការវិនិយោគទុន និងលើកកំពស់ជីវភាពរបស់ប្រជាជនចិន។ លោកពុំរំពឹងថា កំណើនសេដ្ឋកិច្ចចិន ( **GDP** ) នឹងកើនបាន២ខ្ទង់នោះទេ។ ផ្អែកតាមការទោះទាយរបស់សេដ្ឋវិទូរបស់ចិនមួយចំនួនបានថ្លែងថា ទីផ្សារធំរបស់ចិនគឺទីផ្សារសហគមន៍អឺរ៉ុបនិងសហរដ្ឋអាមេរិក ដូច្នេះ គេរំពឹងថា ទីផ្សាររបស់ចិននឹងល្អឡើងវិញដោយវិបត្តិបំណុលនៅអឺរ៉ុប និងអាមេរិកត្រូវបានដោះស្រាយ ។

**Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China**
**Tel/Fax : +86-771-5389496**
**Email : clo_cambodia@yahoo.com**

ដោយផ្អែកតាមទូរលេខរបស់ធនាគាជាតិចិន ( **Bank of China** ) បានបញ្ជាក់ថាចាប់ពីឆ្នាំ២០១២នេះការទូរទាត់រូបិយប័ណ្ណផ្អែកវិនិយោគនិងពាណិជ្ជកម្មដោយប្រើប្រាស់ប្រាក់យ័ន់ចិនមានការកើនឡើង។ កត្តាដែលការទូរទាត់ជាប្រាក់យ័ន់កើនឡើងដោយរដ្ឋាភិបាលចិនបានបន្ធូរបន្ថយការត្រួតពិនិត្យគណនីមូលធន ពោលគឺទំហំទឹកប្រាក់ក្នុងការវិនិយោគនិងឥណទានដែលនាំចូលមកចិន។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១២ ការទូរទាត់ពាណិជ្ជកម្មជាប្រាក់យ័ន់តាមទល់ដែនសំរេចបាន២.៩៤លានលានយ័ន់ ឯការទូរទាត់ផ្អែកវិនិយោគជាប្រាក់យ័ន់កើនបានជាង២៨០លានលានយ័ន់ ស្មើនឹង១៥៣%ខ្ពស់ជាងឆ្នាំ២០១១ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំ**ខែមករា ឆ្នាំ២០១៣** ដ៏ខ្ពង់ខ្ពស់ដោយអនុគ្រោះ ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ណាននីង.ថ្ងៃទី.01..ខែ.02.ឆ្នាំ២០១៣

**ទីប្រឹក្សាពាណិជ្ជកម្ម**

**អ៊ុច គីមយ៉ុន**

<u>ចម្លងជូន:</u>

-អគ្គកុងស៊ុលនៅណាននីង

-ឯកសារកាលប្បវត្តិ

Address: No 11, Zhujin Road, China-ASEAN Business District,
Nanning City, Guangxi, China

Tel/Fax : +86-771-5389496
Email : clo_cambodia@yahoo.com